ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...........សហវ.......

ប្រកាសអន្តរក្រសួង
ស្តីពី
ការប្រើប្រាស់ថវិកា សម្រាប់ប្រាក់រង្វាន់លើកទឹកចិត្ត
និងពង្រឹងយន្តការនៃការគៀរគរ និងប្រមូលចំណូលសួយសារផលិតផលរ៉ែ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ

នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- ប្រកាសលេខ ១១២៥ សហវ.ប្រក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៨ ស្ដីពីការបង្កើតក្រុមការងារទារបំណុលថ្លៃឈ្នួលទីតាំងអចលនវត្ថុរដ្ឋ និងចំណូលមិនមែនសារពើពន្ធរបស់ក្រសួងរ៉ែ និងថាមពល
- យោងតាមតម្រូវការចាំបាច់នៃការងារ

## សម្រេច

**ប្រការ ១.~**

ត្រូវបានអនុញ្ញាតឱ្យក្រសួងរ៉ែ និងថាមពល កាត់ទុកជាមុនចំនួន ១០% (ដប់ភាគរយ) នៃប្រាក់ចំណូលសួយសារផលិតផលរ៉ែ(ហៅកាត់ថា“ប្រាក់កាត់ទុក”) ដើម្បីប្រើប្រាស់ជាប្រាក់រង្វាន់លើកទឹកចិត្ត និងពង្រឹងយន្តការនៃការកៀរគរ និងប្រមូលចំណូលសួយសារផលិតផលរ៉ែ។ ចំណែក៩០% (កៅសិបភាគរយ) នៃប្រាក់ចំណូលសួយសារផលិតផលរ៉ែដែលនៅសល់ ត្រូវបង់ និងកត់ត្រាក្នុងចំណូលរបស់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ស្របតាមការកំណត់ក្នុងប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរ៉ែនិងថាមពល ស្ដីពីអត្រាសួយសារលើតម្លៃផលិតផលរ៉ែ និងនីតិវិធីនៃការបង់ថ្លៃសួយសារ ដែលមានជាធរមាន។

**ប្រការ ២.~**

ប្រាក់រង្វាន់ចំនួន ១០% នៃចំណូលសួយសារផលិតផលរ៉ែ ត្រូវបង់ចូលក្នុងគណនីចរន្តនៅធនាគារពាណិជ្ជដៃគូ (រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរ៉ែនិងថាមពល)។ ក្រសួងរ៉ែ និងថាមពលត្រូវធ្វើការបែងចែកប្រាក់រង្វាន់ចំនួន ១០% នៃចំណូលសួយសារផលិតផលរ៉ែ ជូនតាមបណ្ដាអង្គភាពគោលដៅតាមការកំណត់ក្នុងប្រការ ៣ នៃប្រកាសអន្តរក្រសួងនេះ ព្រមទាំងសម្រាប់បើកផ្ដល់លើកទឹកចិត្តដល់មន្ត្រីរាជការនៃក្រសួងរ៉ែ និងថាមពល។

**ប្រការ ៣.~**

ប្រាក់កាត់ទុក ត្រូវចាត់ចែងបែងចែកដូចខាងក្រោម÷

ក- ចំនួន ៣០% នៃប្រាក់កាត់ទុក ផ្ដល់ជូនក្រសួងរ៉ែ និងថាមពល សម្រាប់ប្រើប្រាស់ជារង្វាន់លើកទឹកចិត្តជូនមន្ត្រីរាជការក្រសួងរ៉ែ និងថាមពល។

ខ- ចំនួន ២០% នៃប្រាក់កាត់ទុក ផ្ដល់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ប្រើប្រាស់ជារង្វាន់លើកទឹកចិត្តជូនមន្ត្រីរាជការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងក្រុមការងារទារបំណុលថ្លៃឈ្នួល

ទីតាំងអចលនវត្ថុរដ្ឋ និងចំណូលមិនមែនសារពើពន្ធ របស់ក្រសួងរ៉ែ និងថាមពល (ហៅកាត់ថា "ក្រុមការងារទារបំណុលអន្តរក្រសួង") ដែលត្រូវបានបង្កើតឡើងដោយប្រកាសលេខ ១១២៥ សហវ.ប្រក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

គ- ចំនួន ១០% នៃប្រាក់កាត់ទុក ផ្តល់ជូនរដ្ឋបាលរាជធានី ខេត្ត និងអង្គភាពថ្នាក់ក្រោមជាតិពាក់ព័ន្ធ សម្រាប់ប្រើប្រាស់ជារង្វាន់លើកទឹកចិត្តជូនមន្ត្រីរាជការ ដែលបានចូលរួមផ្ទាល់ក្នុងការងារកៀរគរ និងប្រមូលចំណូលសួយសារផលិតផលរ៉ែ។

ឃ- ចំនួន ៦% នៃប្រាក់កាត់ទុក ផ្តល់ជូនមន្ទីររ៉ែ និងថាមពល រាជធានី ខេត្តសាមីពាក់ព័ន្ធ សម្រាប់ប្រើប្រាស់ជារង្វាន់លើកទឹកចិត្តជូនមន្ត្រីរាជការ ដែលបានចូលរួមផ្ទាល់ ក្នុងការងារកៀរគរ និងប្រមូលចំណូលសួយសារផលិតផលរ៉ែ។

ង- ចំនួន ៤% នៃប្រាក់កាត់ទុក ផ្តល់ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានី ខេត្តសាមីពាក់ព័ន្ធ សម្រាប់ប្រើប្រាស់ជារង្វាន់លើកទឹកចិត្តជូនមន្ត្រីរាជការ ដែលបានចូលរួមផ្ទាល់ ក្នុងការងារកៀរគរ និងប្រមូលចំណូលសួយសារផលិតផលរ៉ែ។

ច- ចំនួន ២០% នៃប្រាក់កាត់ទុក ត្រូវប្រើប្រាស់សម្រាប់ចំណាយចាំបាច់នានា ក្នុងក្រសួងរ៉ែ និងថាមពល ដើម្បីពង្រឹងយន្តការនៃការកៀរគរ និងប្រមូលចំណូលសួយសារផលិតផលរ៉ែ ឱ្យមានប្រសិទ្ធភាព។

ឆ- ចំនួន ១០% នៃប្រាក់កាត់ទុក ត្រូវប្រើប្រាស់សម្រាប់ចំណាយចាំបាច់នានា ក្នុងក្រុមការងារទារបំណុលអន្តរក្រសួង ដើម្បីពង្រឹងយន្តការនៃការកៀរគរ និងប្រមូលចំណូលសួយសារផលិតផលរ៉ែ ឱ្យមានប្រសិទ្ធភាព។ ក្រុមការងារទារបំណុលអន្តរក្រសួង ត្រូវប្រើប្រាស់ថវិកានេះ សម្រាប់ចំណាយចាំបាច់នានា និងចំណាយបេសកកម្ម សម្រាប់សមាជិកក្រុមការងារទារបំណុលអន្តរក្រសួងមកពីក្រសួងស្ថាប័ននានា រួមទាំងរដ្ឋបាលមូលដ្ឋាន និងកងកម្លាំងប្រដាប់អាវុធ ដែលចូលរួមក្នុងការងារកៀរគរប្រមូលចំណូលសួយសារផលិតផលរ៉ែ និងការអនុវត្តវិធានការតឹងទារបំណុល ដោយមិនប្រើប្រាស់ថវិការដ្ឋឡើយ។

**ប្រការ ៤.-**

ការគ្រប់គ្រង និងបែងចែក ប្រាក់កាត់ទុក ដូចមានចែងក្នុងចំណុច ក ចំណុច ឃ និងចំណុច ច នៃប្រការ ៣ ខាងលើ ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល។

ការគ្រប់គ្រង និងបែងចែក ប្រាក់កាត់ទុក ដូចមានចែងក្នុងចំណុច ខ ចំណុច ង និងចំណុច ឆ នៃប្រការ ៣ ខាងលើ ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ប្រធានក្រុមការងារទារបំណុលអន្តរក្រសួង។

ការគ្រប់គ្រង និងបែងចែក ប្រាក់កាត់ទុក ដូចមានចែងក្នុងចំណុច គ នៃប្រការ ៣ ខាងលើ ត្រូវសម្រេចដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្តសាមីពាក់ព័ន្ធ។

**ប្រការ ៥.-**

ប្រកាសអន្តរក្រសួងលេខ ៥១៦ សហវ.ប្រក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការប្រើប្រាស់ថវិកាសម្រាប់ប្រាក់រង្វាន់លើកទឹកចិត្ត និងពង្រឹងយន្តការនៃការកៀរគរ និងប្រមូលចំណូលសួយសារធនធានរ៉ែ និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៦.-**

ប្រកាសអន្តរក្រសួងនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០តទៅ។

**ប្រការ ៧.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងរ៉ែនិងថាមពល អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសអន្តរក្រសួងនេះ ឱ្យមានប្រសិទ្ធភាព។

ថ្ងៃពុធ ១១ កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងរ៉ែ និងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- រដ្ឋបាលរាជធានី-ខេត្ត
- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ